ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ៥ រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃ ២០ ខែ សីហា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ)
## ស្តីពីលទ្ធភាពក្នុងការកែច្នៃសំរាមសម្រាប់ផលិតអគ្គិសនី

នាព្រឹកថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន **គ.ស.ហ** មានរៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាអំពី **"លទ្ធភាពក្នុងការកែច្នៃសំរាមសម្រាប់ផលិតអគ្គិសនី"** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមរដ្ឋមន្ត្រីដឹកនាំជាន់ខ្ពស់នៃក្រសួង-ស្ថាប័ន ពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

ស្របពេលដែលប្រទេសកម្ពុជាកំពុងមានកំណើនសេដ្ឋកិច្ច និងកំណើនប្រជាជននៅតាមទីក្រុង និងទីប្រជុំជនជាពិសេស ក្នុងរាជធានីភ្នំពេញ, បរិមាណសំរាម និងកាកសំណល់រឹងមានការកើនឡើងយ៉ាងខ្លាំងគួរឱ្យព្រួយបារម្ភ ។ ជាក់ស្តែង, ក្នុងរាជធានីភ្នំពេញ, ក្នុងអំឡុងពេល ៥ ឆ្នាំចុងក្រោយនេះ, បរិមាណសំរាមជាមធ្យមចំនួនប្រមាណជាង ២.៨០០ តោនក្នុង ១ ថ្ងៃ ដែលមានការកើន ឡើងក្នុងរង្វង់ពី ១០% ទៅ ១៣% ក្នុង ១ ឆ្នាំ ។ បរិមាណសំរាមក្នុងទីក្រុងត្រូវបានព្យាករណ៍ថានឹងមានការកើនឡើងបន្តទៀត ដែលទាមទារឱ្យមានវិធានការក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ។

កិច្ចប្រជុំបានពិភាក្សា និងរិះរកវិធានការដោះស្រាយបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំរាម និងកាកសំណល់រឹង ដោយផ្អែកលើរបាយការណ៍សិក្សាបឋមរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ហ** ដូចខាងក្រោម÷

១. រៀបចំកសាងក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងអនុវត្តបទដ្ឋានគតិយុត្តិស្តីពីការគ្រប់គ្រងកាកសំណល់រឹង និង សំរាម,
២. រៀបចំយន្តការអន្តរស្ថាប័ន រួមគ្នាអនុវត្តវិធានការណ៍ជាខ្សែច្រវាក់ ចាប់ពីអ្នកប្រើប្រាស់ រហូតដល់ការកែច្នៃចុងក្រោយចំពោះកាកសំណល់រឹង និងសំរាម,
៣. រៀបចំជាយុទ្ធនាការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងគ្រប់ទីកន្លែង ដើម្បីបង្កើនការយល់ដឹង អំពីការទុកដាក់សំរាម ការសំអាតអនាម័យ បរិស្ថាន និងសុខុមាលភាពជារួម ដែលកិច្ចការនេះ ទាមទារឱ្យមានការចូលរួមគាំទ្រឱ្យបានពេញ ទំហឹងពីសំណាក់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ និងភាគីពាក់ព័ន្ធទាំងអស់ ។

អង្គប្រជុំ ក៏បានពិភាក្សាលើជម្រើសនៃវិធានការនានា ដែលមានលក្ខណៈជាប្រព័ន្ធដែលផ្តោតសំខាន់លើ÷

- រៀបចំគោលនយោបាយជាតិស្តីពីការគ្រប់គ្រង និងកែច្នៃសំណល់រឹង និងសំរាម,
- កែសម្រួលប្រព័ន្ធគ្រប់គ្រង ដាក់ចេញនូវយន្តការ វិធានការអនុវត្តម៉ត់ចត់ និងជាក់លាក់ក្នុងការគ្រប់គ្រងកាកសំណល់រឹង និងសំរាម ក៏ដូចជា រៀបចំជាយុទ្ធនាការដើម្បីផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋ ដោយមានការសហការពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ចូលរួមរៀបចំទុកដាក់កាកសំណល់រឹង និងសំរាម ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ ក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានខិតខំ និងចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ស្វែងរកដំណោះស្រាយ សម្រាប់ការអនុវត្ត និងបានស្នើឱ្យគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តចូលរួមផ្តល់កិច្ចសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។